ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# របាយការណ៍ជាតិលើកទី១និងទី២

# ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារ

# ស្តីពី

# ការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ

ឆ្នាំ២០០២ដល់២០១០

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ

នាថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១១


រៀបចំដោយ

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

# មាតិកា

ទំព័រ


សេចក្តីផ្តើម ........................................ ១

ព័ត៌មានទូទៅ ........................................ ២

ការបង្ការ ........................................ ៤

ការហាមឃាត់ ........................................ ១៣

កិច្ចការពារ ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្ម ........................................ ១៤

ជំនួយនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ ........................................ ១៦

បទប្បញ្ញត្តិច្បាប់ដទៃទៀត ........................................ ១៧

សេចក្តីសន្និដ្ឋាន ........................................ ១៩

## សេចក្តីផ្តើម

១- ព្រះរាជាណាចក្រកម្ពុជាមានប្រជាជនសរុបចំនួន១៣ ៣៩៥ ៦៨២នាក់នៅឆ្នាំ២០០៨ (ស្រីមានចំនួន៦ ៨៧៩ ៦២៨នាក់និងប្រុស៦ ៥១៦ ០៥៤នាក់) ក្នុងនោះកុមារអាយុក្រោម១៨ឆ្នាំមានចំនួន ៥ ៨៨៧ ៧០៨នាក់ និងអត្រាកំណើនប្រជាជនប្រចាំឆ្នាំជាមធ្យមគឺ១,៥៤ភាគរយ។ ដង់ស៊ីតេប្រជាជនទូទាំងប្រទេសមាន៧៥នាក់ក្នុង១គម[២]។ អត្រាលទ្ធភាពបង្កើតកូនសរុបក្នុងស្ត្រីម្នាក់ៗមាន៣,១ នៅឆ្នាំ២០០៨។ ចាប់ពីឆ្នាំ២០០០ដល់ឆ្នាំ២០០៨ អត្រាមរណភាពទារកធ្លាក់ចុះពី៩៥មក៦០ក្នុង១ ០០០ កំណើតរស់ និងអត្រាមរណភាពមាតាធ្លាក់ចុះពី៤៧២មក៤៦១ក្នុង១០០ ០០០ កំណើតរស់ [១]។

២- ចាប់តាំងពីឆ្នាំ១៩៩៣ ផលិតផលក្នុងស្រុកសរុបកើន០៤ដង ពី២,៨៣ពាន់លានដុល្លារ ឡើងដល់១០,៣ ពាន់លានដុល្លារនៅឆ្នាំ២០០៨។ ក្នុងរយៈពេលនេះ ចំណូលជាមធ្យមនៃប្រជាជនម្នាក់ៗបានកើនឡើង០៣ដង ពី២២៩ដុល្លារឡើងដល់៧៣៩ដុល្លារ។ អត្រានៃភាពក្រីក្រធ្លាក់ចុះពីប្រមាណ៥០ភាគរយនៅឆ្នាំ១៩៩៣ មកត្រឹម២៥,៨ ភាគរយនៅឆ្នាំ២០១០[២]។

៣- ក្រោយពីសង្គ្រាមស៊ីវិលជាង២ទសវត្សរ៍ ព្រះរាជាណាចក្រកម្ពុជាបានចាប់ផ្តើមបង្កើតប្រព័ន្ធច្បាប់និងតុលាការឡើងវិញពីបាតដៃទទេ។ រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តខ្ពស់ក្នុងការលើកស្ទួយសិទ្ធិកុមារតាមរយៈការបង្កើតបរិយាកាសល្អប្រសើរ សម្រាប់ការរស់រានមានជីវិតនិងការអភិវឌ្ឍ ការពង្រឹងសុខុមាលភាពកុមារ និងការបង្កើនបរិយាកាសការពារយ៉ាងរឹងមាំដល់កុមារ។ សកម្មភាពជាច្រើនត្រូវបានអនុវត្តព្រមៗគ្នា ដូចជាការបង្កើតនិងពង្រឹងក្របខ័ណ្ឌគោលនយោបាយ ច្បាប់ យន្តការ។ ក្រៅពីក្រសួងនិងស្ថាប័នជំនាញពាក់ព័ន្ធ យន្តការពិសេសជាច្រើនត្រូវបានបង្កើតដើម្បីធានាឲ្យកុមារទទួលបានសិទ្ធិរបស់ខ្លួនយ៉ាងពេញលេញ ដូចជាក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ ក្រុមការងារពហុវិស័យស្តីពីកុមារកំព្រានិងកុមារងាយរងគ្រោះ ក្រុមការងារយុត្តិធម៌កុមារ និងក្រុមការងារអង្គការមិនមែនរដ្ឋាភិបាលដើម្បីយុត្តិធម៌កុមារជាដើម។ យន្តការទាំងនេះ មានចាប់តាំងពីថ្នាក់ជាតិ រាជធានី ខេត្ត រហូតដល់ថ្នាក់ឃុំ សង្កាត់ដែលជាទីកន្លែងកុមាររស់នៅ។

៤- ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ និងបានផ្តល់សច្ចាប័នលើពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការចូលរួមរបស់កុមារ នៅក្នុងជម្លោះប្រដាប់អាវុធនៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០២។ ឯកសារនេះជារបាយការណ៍លើកទី១និងទី២ ដែលបរិយាយពីការអនុវត្តពិធីសារចន្លោះពីឆ្នាំ២០០២ដល់ឆ្នាំ២០១០។

៥- រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣នៃព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។ រដ្ឋធានាក្សា

---

[១] ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨

[២] យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ (២០១១-២០១៥)

ការពារសិទ្ធិរបស់កុមារដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ចឬកាមគុណលើកុមារ។ ការដាក់បញ្ចូលអនុសញ្ញាស្តីពីសិទ្ធិកុមារទៅក្នុងរដ្ឋធម្មនុញ្ញ ជាការផ្តល់នូវឋានៈដល់បទប្បញ្ញត្តិនៃអនុសញ្ញានេះឲ្យមានតម្លៃស្មើនឹងច្បាប់ជាតិ និងជានាឲ្យសិទ្ធិទាំងអស់ រួមទាំងគោលការណ៍ទូទៅរបស់អនុសញ្ញាស្តីពីសិទ្ធិកុមារដែលក្នុងនោះ រួមមាន ការមិនរើសអើង ឧត្តមប្រយោជន៍កុមារ សិទ្ធិរបស់កុមារក្នុងការមានជីវិត ការទទួលបានការរស់រានការអភិវឌ្ឍ និងការគោរពទស្សនៈរបស់កុមារ មានលក្ខណៈជាកាតព្វកិច្ចតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។ យោងតាមច្បាប់ស្តីពីកាតព្វកិច្ចយោធាដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣០ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៦ និងច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ មានតែជនដែលមានអាយុពី១៨ឆ្នាំដល់៣០ឆ្នាំ ទើបច្បាប់តម្រូវឲ្យបំពេញកាតព្វកិច្ចយោធា ហើយយោធិនជាប់កិច្ចសន្យាត្រូវបានជ្រើសរើសចំពោះជនណាដែលមានសញ្ជាតិខ្មែរអាយុគ្រប់១៨ឆ្នាំ។

៦- ក្នុងអំឡុងពេលប៉ុន្មានឆ្នាំកន្លងទៅនេះ ស្ថានភាពកុមារនិងស្ត្រីមានការរីកចម្រើនយ៉ាងប្រសើរបើប្រៀបធៀបទៅនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ មានការរីកចម្រើនក្នុងការធ្វើវិមជ្ឈការអំណាចទៅដល់ថ្នាក់មូលដ្ឋានដើម្បីឆ្លើយតបឲ្យកាន់តែប្រសើរឡើងដល់តម្រូវការរបស់ពលរដ្ឋនៅមូលដ្ឋាន។ អត្រាកុមារចុះឈ្មោះចូលរៀនសរុបនៅបឋមសិក្សាមានការរីកចម្រើនគួរឲ្យកត់សម្គាល់ ហើយវិសមភាពយេនឌ័រគិតលើតួលេខក៏បានថយចុះដែរ។ នៅឆ្នាំសិក្សា២០០៩-២០១០ អត្រាពិតនៃការសិក្សានៅបឋមសិក្សានៃកុមារទាំងពីរភេទមាន៩៤,៨ភាគរយ។

## ព័ត៌មានទូទៅ

៧- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានបង្កើតក្រុមការងារមួយ ដែលមានសមាសភាពមកពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងយុត្តិធម៌ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រសួងទេសចរណ៍ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងផែនការ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រុមប្រឹក្សាអ្នកច្បាប់ អ្នកតំណាងមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ(UNICEF) អ្នកតំណាងគម្រោងអន្តរៈទីភ្នាក់ងារសហប្រជាជាតិប្រឆាំងអំពើជួញដូរមនុស្ស(UNIAP) គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ(NGOCRC) គណៈកម្មាធិការបំបាត់ពេស្យាចារ ការរំលោភនិងជួញដូរកុមារនៅកម្ពុជា(ECPAT) សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលដើម្បីដោះស្រាយបញ្ហាជួញដូរនិងកេងប្រវ័ញ្ចផ្លូវភេទលើកុមារក្នុងប្រទេសកម្ពុជា (COSECAM) និងសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលប្រឆាំងការជួញដូរកុមារនៅកម្ពុជា(Cambodia ACTs) ដើម្បីសរសេររបាយការណ៍ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការចូលរួមរបស់

កុមារនៅក្នុងជម្លោះប្រដាប់អាវុធ។ ក្រុមការងារនេះអាចអនុញ្ញាតឲ្យអង្គការមិនមែនរដ្ឋាភិបាលនិងអង្គការអន្តរជាតិផ្សេងទៀតចូលរួមផ្តល់យោបល់លើរបាយការណ៍។ របាយការណ៍នេះត្រូវបានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារធ្វើការពិគ្រោះយោបល់ ដើម្បីស្វែងរកការផ្តល់មតិបន្ថែមពីកុមារពីសំណាក់ ១៦រាជធានី ខេត្ត តាមរយៈវេទិកាកុមារថ្នាក់ជាតិដែលបានប្រព្រឹត្តទៅនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១០ និងពីសំណាក់អ្នកដែលធ្វើការងារពាក់ព័ន្ធមកពីក្រសួង ស្ថាប័ន និងអង្គការមិនមែនរដ្ឋាភិបាល តាមរយៈសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១០។ មតិរបស់កុមារនិងអ្នកធ្វើការងារពាក់ព័ន្ធត្រូវបានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារយកមកពិចារណាយ៉ាងល្អិតល្អន់ក្នុងការធ្វើរបាយការណ៍នេះ។

៨- ពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ ត្រូវបានចាត់ទុកថាជាផ្នែកមួយនៃច្បាប់ជាតិ។ ក្រុមប្រឹក្សាធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់កាតព្វកិច្ចរបស់កម្ពុជាដោយអនុលោមទៅតាមអនុសញ្ញាអន្តរជាតិនានា។ ក្រុមប្រឹក្សាធម្មនុញ្ញបានចេញសេចក្តីសម្រេចលេខ០៩២/០០៣/២០០៧ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ ដោយកំណត់ថាច្បាប់អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់រួចមកហើយ ជាពិសេសអនុសញ្ញាស្តីពីសិទ្ធិកុមារត្រូវបានចាត់ទុកថាជាផ្នែកមួយនៃច្បាប់ជាតិរបស់កម្ពុជា។

៩- ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធដោយពុំមានដាក់ខបម្រុងឡើយ។

១០- មានតែរបបកម្ពុជាប្រជាធិបតេយ្យ (របបប៉ុលពត ១៩៧៥-១៩៧៩) ប៉ុណ្ណោះ ដែលបានជ្រើសរើសយោធិនជាកុមារ និងត្រូវបានដឹងឮជាទូទៅ។ បច្ចុប្បន្ននេះកងយោធពលខេមរភូមិន្ទនិងកងនគរបាលជាតិរបស់រាជរដ្ឋាភិបាលពុំមានយោធិននិងនគរបាលជាកុមារឡើយ។

១១- ការបម្រើទ័ពជាកាតព្វកិច្ចតាមផ្លូវច្បាប់សម្រាប់តែពលរដ្ឋខ្មែរដែលមានអាយុពី១៨ឆ្នាំដល់៣០ឆ្នាំតែប៉ុណ្ណោះ។ ដូច្នេះ ពុំមានទិន្នន័យស្តីពីចំនួនកុមារអាយុក្រោម១៨ឆ្នាំ ដែលត្រូវបានជ្រើសរើសឲ្យចូលបម្រើដោយស្ម័គ្រចិត្តនៅក្នុងកងទ័ពជាតិ និងចំនួនកុមារដែលត្រូវបានរំសាយនិងធ្វើសមាហរណកម្ម ព្រមទាំងទិន្នន័យអំពីចំនួនកុមាររងគ្រោះពីការអនុវត្តដែលត្រូវបានហាមឃាត់ដោយពិធីសារក្នុងចំណោមជនភៀសខ្លួននិងអ្នកស្វែងរកសិទ្ធិជ្រកកោនឡើយ។

១២- ក្រសួង ស្ថាប័នដែលទទួលខុសត្រូវក្នុងការអនុវត្តពិធីសារនិងធ្វើការសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងជាមួយអង្គការសង្គមស៊ីវិល ដោយគិតទាំងប្រព័ន្ធផ្សព្វផ្សាយនិងគ្រឹះស្ថាននានា រួមមានក្រសួងការពារជាតិដែលជាស្ថាប័នសំខាន់ជាងគេទាក់ទងនឹងជម្លោះប្រដាប់អាវុធ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមហាផ្ទៃ និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។

១៣- រាជរដ្ឋាភិបាលកម្ពុជាបានធ្វើសកម្មភាពផ្សព្វផ្សាយអំពីពិធីសារនេះនិងលិខិតុបករណ៍ពាក់ព័ន្ធនឹងសិទ្ធិមនុស្សក្នុងមជ្ឈដ្ឋានកងយោធពលខេមរភូមិន្ទនិងសាធារណជន។ ចំពោះការបណ្តុះបណ្តាលវិញមិនមានការបណ្តុះបណ្តាលទាក់ទិននឹងពិធីសារនេះជាប្រព័ន្ធទេ ប៉ុន្តែមានការបណ្តុះបណ្តាលធ្វើឡើងសម្រាប់បុគ្គលិកយោធា ដោយមានបញ្ចូលនូវកម្មវិធីបង្រៀនពីសិទ្ធិកុមារនិងច្បាប់សិទ្ធិ

មនុស្សអន្តរជាតិ។ ការបោះពុម្ពផ្សាយពិធីសារត្រូវបានដាក់បញ្ចូលក្នុងកម្រងឯកសារទាក់ទងនឹងសិទ្ធិកុមារ។ ពិធីសារនេះត្រូវបានផ្សព្វផ្សាយនៅក្នុងចំណោមសិក្ខាកាម តាមរយៈសិក្ខាសាលានិងការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់។ ក្រុមអ្នកដោះមីនដែលត្រូវបំពេញបេសកកម្មរក្សាសន្តិភាពនៅក្រៅប្រទេសនិងគ្រូឧទ្ទេសជាយោធិន បានទទួលការបណ្តុះបណ្តាលអំពីសន្ធិសញ្ញាអន្តរជាតិចម្បងៗស្តីអំពីសិទ្ធិមនុស្សនិងច្បាប់មនុស្សធម៌ ជាអាទិ៍៖

- អនុសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងពិធីសារបន្ថែមនានានៃអនុសញ្ញានេះ
- អនុសញ្ញាស្តីពីសិទ្ធិកុមារឆ្នាំ១៩៨៩ និងពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ
- អនុសញ្ញាលេខ១៨២ ស្តីពីការហាមប្រាមនិងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ របស់អង្គការពលកម្មអន្តរជាតិ(ILO) ឆ្នាំ១៩៩៩ និង
- លក្ខន្តិកៈក្រុងរ៉ូមនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិឆ្នាំ២០០២។

អត្ថបទជាភាសាខ្មែរនៃពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ ត្រូវបានបង្ហោះក្នុងគេហទំព័រដែលអាចឲ្យសាធារណជនទូទៅរកបាន។

១៤- ក្រោយពីព្រះរាជាណាចក្រកម្ពុជាទទួលបានសន្តិភាព បន្ទាប់ពីមានកិច្ចព្រមព្រៀងទីក្រុងប៉ារីស នាឆ្នាំ១៩៩១ និងបន្ទាប់ពីការបោះឆ្នោតឆ្នាំ១៩៩៣ ពុំមានកុមារណាម្នាក់ដែលត្រូវបានជ្រើសរើសដោយការស្ម័គ្រចិត្តចូលក្នុងកងកម្លាំងប្រដាប់អាវុធជាតិឡើយ ហើយរហូតមកទល់ពេលនេះពុំមានកុមារណាម្នាក់ក្នុងចំណោមជនភៀសខ្លួននិងអ្នកស្វែងរកសិទ្ធិជ្រកកោនក្លាយជាជនរងគ្រោះដោយសារការអនុវត្តពិធីសារដែលត្រូវបានហាមឃាត់ឡើយ។

១៥- គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ជាស្ថាប័នមួយរបស់រាជរដ្ឋាភិបាលដែលមានភារកិច្ចដើម្បីរក្សាការពារ អភិវឌ្ឍ និងលើកតម្កើងវិស័យសិទ្ធិមនុស្សនៅកម្ពុជាស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ហើយមានតួនាទី ជាអាទិ៍៖

- ការពារ លើកស្ទួយ អភិវឌ្ឍសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ត្រួតពិនិត្យរាល់ការរំលោភសិទ្ធិមនុស្ស និងបណ្តឹងតវ៉ានានា
- ស្រាវជ្រាវ អង្កេតករណីនានា ឬធ្វើការវាយតម្លៃលើការស្រាវជ្រាវ ការអង្កេតរបស់សមត្ថកិច្ច ឬធ្វើសហការស្រាវជ្រាវជាមួយសមត្ថកិច្ច ហើយធ្វើសំណុំឯកសារផ្សព្វផ្សាយជូនសាធារណជន ជូននាយករដ្ឋមន្ត្រី ជូនតុលាការ ជូនសមត្ថកិច្ចនោះវិញ
- ចុះពិនិត្យតាមមូលដ្ឋាននានា ដើម្បីធ្វើការវាយតម្លៃនិងផ្តល់ឱវាទអំពីសិទ្ធិមនុស្ស
- អប់រំផ្សព្វផ្សាយជាសាធារណៈនិងតាមមុខសញ្ញានីមួយៗ
- ផ្តល់យោបល់និងលើកសំណើជូនរាជរដ្ឋាភិបាលអំពីសភាពការណ៍សិទ្ធិមនុស្ស សំដៅធ្វើការកែលំអ និងធ្វើយ៉ាងណាឲ្យកាន់តែសមស្របនឹងរដ្ឋធម្មនុញ្ញ ច្បាប់ប្រទេស និងអនុសញ្ញាទាំងឡាយរបស់អន្តរជាតិ
- ធ្វើសហការជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារនិងក្រសួងកិច្ចការនារីដែលជាស្ថាប័នទទួល

ខុសត្រូវអំពីសិទ្ធិកុមារនិងសិទ្ធិនារី

- ជួយដល់រាជរដ្ឋាភិបាលក្នុងការជំរុញការងារនីតិរដ្ឋនិងការបណ្តុះបណ្តាលអ្នកច្បាប់
- គាំទ្រធ្វើសហការជាមួយអង្គការសង្គមស៊ីវិល ដើម្បីបុព្វហេតុការពារនិងអភិវឌ្ឍវិស័យសិទ្ធិមនុស្ស នៅកម្ពុជា។

១៦- ពុំមានបញ្ហាប្រឈមនិងកត្តាដែលរាំងស្ទះគួរឲ្យកត់សម្គាល់ដល់ការអនុវត្តពិធីសារនៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ។

**ការបង្ការ**

ឆ្លើយតបនឹងមាត្រា១ មាត្រា២ និងមាត្រា៤ កថាខណ្ឌ២ក និងមាត្រា៦ កថាខណ្ឌទី២នៃពិធីសារបន្ថែម។

១៧- ច្បាប់និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗទាក់ទងនឹងកម្លាំងប្រដាប់អាវុធ ដែលត្រូវបានអនុម័តនិងប្រកាសឲ្យប្រើ រួមមាន៖

១- មាត្រា៤៩នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ចែងថា " ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិនិងការពារមាតុភូមិ។ កាតព្វកិច្ចការពារមាតុភូមិត្រូវអនុវត្តតាមបញ្ញត្តិច្បាប់"។

២- ច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទឆ្នាំ១៩៩៧ ចែងថា " កងយោធពលខេមរភូមិន្ទមានភារកិច្ចបម្រើប្រទេស។ បេសកកម្មរបស់កងយោធពលខេមរភូមិន្ទគឺត្រូវរៀបចំប្រើប្រាស់កម្លាំងកងយោធពលខេមរភូមិន្ទ ដើម្បីការពារ កសាងមាតុភូមិ និងដើម្បីផលប្រយោជន៍ដ៏ខ្ពង់ខ្ពស់របស់ប្រទេសជាតិ "។

៣- ច្បាប់ស្តីពីការផ្តន្ទាទោសការប្រើអាវុធនិងការស្លៀកពាក់ឯកសណ្ឋានខុសពីបទបញ្ជាឆ្នាំ១៩៩២

៤- ច្បាប់ស្តីពីកាតព្វកិច្ចយោធាឆ្នាំ២០០៦ មានគោលដៅកំណត់បែបបទការអនុវត្តកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិនិងការពារមាតុភូមិដូចមានចែងក្នុងមាត្រា៤៩នៃរដ្ឋធម្មនុញ្ញ។ កាតព្វកិច្ចយោធាជាករណីយកិច្ចចាំបាច់របស់ប្រជាពលរដ្ឋ ជាមូលដ្ឋានគ្រឹះនៃប្រភពកសាងកម្លាំងសម្រាប់វិស័យការពារជាតិ។

៥- អនុក្រឹត្យលេខ២០០ អនក្រ.បក ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីលក្ខខណ្ឌនិងបែបបទនៃការធ្វើជំរឿន ការជ្រើសរើស ការអញ្ជើញ ការពន្យារពេលសម្រាប់យុវជនកំពុងជាប់ការសិក្សាប្រជាពលរដ្ឋដែលស្ថិតក្នុងករណីពិសេស និងការអនុវត្តច្បាប់ស្តីពីកាតព្វកិច្ចយោធា។

ក្រៅពីនេះ ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញានិងសន្ធិសញ្ញាអន្តរជាតិដែលពាក់ព័ន្ធនឹងការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ មានដូចជា៖

- អនុសញ្ញាលេខ២៩ស្តីពីការងារដោយបង្ខំឬជាកាតព្វកិច្ចឆ្នាំ១៩៧០
- អនុសញ្ញាស្តីពីសិទ្ធិកុមារឆ្នាំ១៩៩២
- អនុសញ្ញាប្រឆាំងការធ្វើទារុណកម្មនិងប្រព្រឹត្តិកម្ម ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោកឆ្នាំ១៩៩២

- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយឆ្នាំ១៩៩២
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ឆ្នាំ១៩៩២
- អនុសញ្ញារបស់អង្គការអន្តរជាតិខាងការងារលេខ១៨២ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារឆ្នាំ២០០៦
- ពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងការធ្វើទារុណកម្មនិងប្រព្រឹត្តិកម្ម ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថាបបន្ថោកឆ្នាំ២០០៧។

១៨- ការជ្រើសរើសយោធិន

១- ការជ្រើសរើសយោធិន

- ច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ចែងពីសេចក្តីសម្រេចដាច់ដោយឡែកសម្រាប់កងកម្លាំងយោធិនអាជីពនិងកងកម្លាំងយោធិនជាប់កិច្ចសន្យា។ មាត្រា៥២នៃច្បាប់នេះបានចែងថា " យោធិនជាប់កិច្ចសន្យាត្រូវបានជ្រើសរើសចំពោះជនណាដែល៖ ១- មានសញ្ជាតិខ្មែរ លើកលែងតែពេលមានសង្គ្រាម ២- មានអាយុគ្រប់១៨ឆ្នាំ និង៣- មានសម្បទាតាមតម្រូវការដើម្បីបំពេញមុខងារ" ។
- ច្បាប់ស្តីពីកាតព្វកិច្ចយោធា ត្រូវបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១២០៦/០៣០ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៦។ ច្បាប់នេះមានគោលបំណងកសាងកងកម្លាំងប្រដាប់អាវុធសម្រាប់វិស័យការពារជាតិនិងការអភិវឌ្ឍកាយសម្បទាដែលជាតម្រូវការរបស់ប្រទេសជាតិ។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទគ្រប់រូបដែលមានអាយុពី១៨ដល់៣០ឆ្នាំត្រូវបំពេញកាតព្វកិច្ចយោធាតាមការកំណត់របស់មាត្រា២នៃច្បាប់នេះ។ មានតែការអប់រំស្មារតីឲ្យស្រឡាញ់ជាតិនិងមាតុភូមិតែប៉ុណ្ណោះ ដែលជាការលើកទឹកចិត្តឲ្យយុវជនបម្រើកងទ័ព។ ជាទូទៅ មិនសូវមានស្ត្រីនៅក្នុងជួរកងកម្លាំងប្រដាប់អាវុធឡើយ។ ស្ត្រីមួយចំនួនតូចចូលបម្រើកងទ័ពតាមរយៈការប្រឡងចូលជាក្របខ័ណ្ឌនាយទាហានសកម្ម។
- សិទ្ធិរបស់កុមារនៅកម្ពុជាបានពង្រឹងយ៉ាងខ្លាំងក្លា ដោយមិនអនុញ្ញាតឲ្យកុមារមានអាយុក្រោម១៨ឆ្នាំចូលរួមនៅក្នុងកងកម្លាំងប្រដាប់អាវុធ ឬចូលរួមដោយផ្ទាល់ក្នុងសង្គ្រាម ឬត្រូវបានជ្រើសរើសជាយោធិនឡើយ។
- មាត្រា៤៨នៃរដ្ឋធម្មនុញ្ញចែងថា"រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេស សិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្ម សេដ្ឋកិច្ច ឬកាមគុណលើកុមារ"។

២- ឯកសារដើម្បីផ្ទៀងផ្ទាត់ការទទួលយកឲ្យបម្រើកាតព្វកិច្ចយោធា

ការធ្វើបញ្ជីជំរឿនកាតព្វកិច្ចយោធាផ្អែកលើឯកសារ ដូចខាងក្រោម៖

- សៀវភៅគ្រួសារឬសៀវភៅស្នាក់នៅ
- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ

- សំបុត្រកំណើត
- ឯកសារផ្សេងៗទៀតដែលបញ្ជាក់សញ្ជាតិខ្មែរ។

សាមីខ្លួនត្រូវទៅចុះឈ្មោះដោយផ្ទាល់ ឬឪពុក ឬម្ដាយ ឬអ្នកអាណាព្យាបាលជាអ្នកទៅចុះឈ្មោះជំនួស។ ការធ្វើបញ្ជីជំរឿនកាតព្វកិច្ចយោធាត្រូវឲ្យធ្វើចំពោះប្រជាពលរដ្ឋគ្រប់រូប។

៣- ការជ្រើសរើសយោធិនអាជីពនិងយោធិនជាប់កិច្ចសន្យា

- យោធិនមានពីរប្រភេទគឺយោធិនអាជីពនិងយោធិនជាប់កិច្ចសន្យា។ ប្រភេទទី១គឺជាយោធិនដែលធ្វើការពេញម៉ោង ហើយប្រភេទទី២គឺជាយោធិនបម្រើក្នុងជួរកងទ័ព ដោយផ្អែកតាមលក្ខខណ្ឌចែងនៅក្នុងកិច្ចសន្យាណាមួយ។ បុគ្គលដែលមានសិទ្ធិនឹងត្រូវបានជ្រើសរើសជាយោធិនជាប់កិច្ចសន្យាគឺជាជនជាតិខ្មែរដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ ហើយត្រូវមានសមត្ថភាពកាយសម្បទាមាំមួននិងស្មារតីក្នុងការបំពេញកាតព្វកិច្ច។ យោធិនប្រភេទទី២នេះ ក្រោយពីបានបញ្ចប់កិច្ចសន្យាហើយ អាចបន្តកិច្ចសន្យាសាជាថ្មីទៀតបាន។

៤- ការចុះសំបុត្រកំណើត

- សំបុត្រកំណើតជាភស្តុតាងមួយសម្រាប់អះអាងពីអាយុពិតប្រាកដ និងធ្វើឲ្យសាមីជនមានសិទ្ធិនិងករណីយកិច្ច។ សៀវភៅគ្រួសារឬអត្តសញ្ញាណបណ្ណជាមធ្យោបាយទូទៅ ដើម្បីផ្ទៀងផ្ទាត់អាយុរបស់បុគ្គលពាក់ព័ន្ធ។ គឺជាករណីកម្រណាស់ដែលប្រជាពលរដ្ឋកម្ពុជាមិនមានឯកសារណាមួយក្នុងចំណោមឯកសារទាំងពីរនេះ។ ក្នុងករណីមិនច្បាស់លាស់ទាក់ទងនឹងអាយុ អ្នកជំនាញផ្នែកសុខាភិបាលឬមន្ត្រីអាជ្ញាធរមូលដ្ឋានត្រូវបានអញ្ជើញឲ្យមកបំភ្លឺ។
- រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ១០៣ស្តីពីអត្រានុកូលដ្ឋាន និងសេចក្តីណែនាំដែលពាក់ព័ន្ធដើម្បីធ្វើឲ្យការចុះបញ្ជីកំណើតកាន់តែប្រសើរឡើង ឧទាហរណ៍ មាត្រា២៥នៃអនុក្រឹត្យលេខ១៧ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៤ បានចែងអំពីការសម្រួលនូវការចុះបញ្ជីកំណើតចំពោះកុមារដែលមិនទាន់បានចុះបញ្ជីក្នុងរយៈពេល៣០ថ្ងៃក្រោយកំណើត។ ក្រមរដ្ឋប្បវេណីដែលតម្រូវឲ្យចុះអត្រានុកូលដ្ឋានកំណើតជាកាតព្វកិច្ចត្រូវបានអនុម័តដោយស្ថាប័ននីតិប្បញ្ញត្តិនៅឆ្នាំ២០០៧។ ក្រសួងមហាផ្ទៃបានជំរុញការផ្សព្វផ្សាយការងារអត្រានុកូលដ្ឋានតាមវិទ្យុនិងទូរទស្សន៍សំដៅបង្កើនការយល់ដឹងនិងការអនុវត្តការងារអត្រានុកូលដ្ឋានឲ្យមានប្រសិទ្ធភាព។ ទន្ទឹមនឹងនោះដែរប្រព័ន្ធរាយការណ៍ត្រូវបានបង្កើតឡើងនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីកត់ត្រាស្ថិតិរបស់ប្រជាជន និងលទ្ធផលនៃការចុះអត្រានុកូលដ្ឋានប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ។ ក្នុងចំណោមប្រជាជនសរុបចំនួន១៣ ៣៩៥ ៦៨២នាក់នៅទូទាំងប្រទេស មានប្រជាជនសរុបចំនួន១២ ៧៨១ ៥៩២នាក់ បានចុះសំបុត្រកំណើតនិងសំបុត្របញ្ជាក់កំណើត ក្នុងនោះចំនួន៨៦៨ ៦៤៣នាក់ បានចុះសំបុត្រកំណើត និង១១ ៩១២ ៩៤៩នាក់ បានចុះសំបុត្របញ្ជាក់កំណើតគិតចាប់ពីឆ្នាំ២០០២ដល់ឆ្នាំ២០០៨។ នៅឆ្នាំ២០០៩ ប្រជាជនចំនួន៩៨ ៧២២នាក់ បានចុះសំបុត្រកំណើត និង១៩៥ ៩១១នាក់ បានចុះសំបុត្របញ្ជាក់កំណើត។ គិតពីខែមករាដល់ខែតុលាឆ្នាំ២០១០ មានប្រជាជនចំនួន៧១ ៥៣៤នាក់ បានចុះសំបុត្រកំណើត និង១៦០ ២៤៧នាក់ បាន

ចុះសំបុត្របញ្ជាក់កំណើត។ គិតពីឆ្នាំ២០០២ដល់ឆ្នាំ២០១០ ប្រជាជនដែលបានចុះសំបុត្រកំណើត និងសំបុត្របញ្ជាក់កំណើត មានដូចខាងក្រោម[៣]៖

| ការចុះសៀវភៅកំណើតនិងសៀវភៅបញ្ជាក់កំណើតទូទាំងប្រទេស | | | | |
|---|---|---|---|---|
| ឆ្នាំ | សរុប | សំបុត្រ កំណើត | សំបុត្រ បញ្ជាក់កំណើត | សំគាល់ |
| ឆ្នាំ២០០២ | ៣៤២ ៧៥៣ | ៣៣ ៣៤០ | ៣០៩ ៤១៣ | សំបុត្រកំណើតផ្តល់ជូនជនដែលបានចុះសៀវភៅកំណើតក្នុងអំឡុងពេលមួយខែក្រោយពេលកើត។ សំបុត្របញ្ជាក់កំណើតផ្តល់ជូនជនដែលចុះសៀវភៅកំណើតបន្ទាប់ពីអំឡុងពេលមួយខែក្រោយពេលកើត។ |
| ឆ្នាំ២០០៣ | ១៨៣ ៣៩០ | ១១ ៤១៤ | ១៧១ ៩៧៦ | |
| ពីខែមករាដល់ខែកញ្ញា ឆ្នាំ២០០៤ | ៨ ០៦៧ ០៣៣ | ៣៤៧ ៦៥៣ | ៧ ៧១៩ ៣៨០ | |
| ពីខែតុលា ឆ្នាំ២០០៤ដល់ខែសីហា ឆ្នាំ២០០៥ | ២ ៧១៤ ២៤៨ | ២៤៨ ៧៦៨ | ២ ៤៦៥ ៤៨០ | |
| ពីខែកញ្ញា ឆ្នាំ២០០៥ដល់ខែសីហា ឆ្នាំ២០០៦ | ៣២៦ ០៩៨ | ៦៥ ១១៤ | ២៦០ ៩៨៤ | |
| ពីខែមករាដល់ខែធ្នូ ឆ្នាំ២០០៧ | ១៤៨ ២៦១ | ៥៩ ០៧៧ | ៨៩ ១៨៤ | |
| ពីខែមករាដល់ខែធ្នូ ឆ្នាំ២០០៨ | ៨០៥ ១២៣ | ៩២ ៩៥៨ | ៧១២ ១៦៥ | |
| ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០០៩ | ២៩៤ ៦៣៣ | ៩៨ ៧២២ | ១៩៥ ៩១១ | |
| ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០១០ | ៣០១ ៦១១ | ៩៥ ៣១៦ | ២០៦ ២៩៥ | |
| សរុប | ១៣ ១៨៣ ១៥០ | ១ ០៥២ ៣៦២ | ១២ ១៣០ ៧៨៨ | |

៥- ការពិនិត្យសុខភាព

- ជាគោលការណ៍ ក្នុងការជ្រើសរើសយោធិន ក្រសួងការពារជាតិតម្រូវឲ្យបុគ្គលដែលដាក់ពាក្យសុំបម្រើក្នុងជួរកងទ័ព ភ្ជាប់មកជាមួយនូវបណ្ណពិនិត្យកាយសម្បទាចេញដោយមន្ទីរពេទ្យរដ្ឋ។ នៅព្រះរាជាណាចក្រកម្ពុជា ច្បាប់មិនតម្រូវឲ្យបុគ្គលដែលមានអាយុក្រោម១៨ឆ្នាំចូលបម្រើក្នុងជួរកងទ័ពជាកាតព្វកិច្ចឡើយ ទោះបីជាប្រទេសស្ថិតក្នុងកាលៈទេសៈមានសង្គ្រាមឬសន្តិភាពក៏ដោយ។

១៩- អាយុអប្បបរមាដែលអាចចូលរៀននៅសាលាបណ្តុះបណ្តាលវិជ្ជាជីវៈយោធិនគឺ១៨ឆ្នាំ។ គ្រឹះស្ថានបណ្តុះបណ្តាលដែលប្រតិបត្តិដោយឬស្ថិតក្រោមការគ្រប់គ្រងរបស់កងកម្លាំងប្រដាប់អាវុធមានដូចខាងក្រោម៖

| គ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈយោធិន | គ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈនគរបាល |
|---|---|
| - សកលវិទ្យាល័យការពារជាតិ | - បណ្ឌិត្យសភានគរបាលកម្ពុជា |
| - វិទ្យាស្ថានទ័ពជើងគោក | - សាលានគរបាលជាតិ |
| - វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ | - សាលាហ្វឹកហ្វឺននគរបាលភូមិភាគ១ ភូមិភាគ២ ភូមិភាគ៣ ភូមិភាគ៤ ភូមិភាគ៥ និងភូមិភាគ៦ |
| - សាលានាយទាហានសកម្ម | |
| - វិទ្យាស្ថានពហុបច្ចេកទេសតេជោ ហ៊ុន សែន | |
| - សាលាកងរាជអាវុធហត្ថ | |

[៣] របាយការណ៍ស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន របស់ការិយាល័យស្ថិតិនិងអត្រានុកូលដ្ឋាននៃក្រសួងមហាផ្ទៃ គិតត្រឹមខែតុលា ឆ្នាំ២០១០

ការបណ្តុះបណ្តាលនៅតាមគ្រឹះស្ថានខាងលើ ត្រូវបានផ្តល់ដល់នីតិជនតែប៉ុណ្ណោះ។ កម្មវិធីសិក្សារបស់គ្រឹះស្ថានបណ្តុះបណ្តាលទាំងនេះ មានបញ្ចូលគោលការណ៍ស្តីពីសិទ្ធិមនុស្សនិងគោលការណ៍មនុស្សធម៌។ វិន័យសាលាត្រូវបានអនុវត្តក្នុងបែបផែនស្របនឹងសេចក្តីថ្លៃថ្នូរបស់មនុស្ស និងស្របតាមអនុសញ្ញាអន្តរជាតិ។ ការអប់រំនៅតាមបណ្តាគ្រឹះស្ថានទាំងនេះ មានគោលដៅលើ ៖

(ក) ការបណ្តុះបណ្តាលជំនាញឯកទេសខាងយោធា ច្បាប់ និងបទបញ្ជាទាក់ទងនឹងយោធិនជំនាញឯកទេសផ្សេងទៀត ដូចជាផ្នែកពេទ្យនិងការស្រាវជ្រាវវិទ្យាសាស្ត្របច្ចេកទេសយោធា។

(ខ) ការអភិវឌ្ឍបុគ្គលិកលក្ខណៈ ទេពកោសល្យ សមត្ថភាពកាយ និងសតិបញ្ញារបស់សិស្ស និស្សិតយោធិនឲ្យដល់សក្តានុភាពសម្រាប់ការការពារជាតិ។

(គ) ការបណ្តុះគំនិតសិស្ស និស្សិតយោធិនឲ្យគោរពសិទ្ធិមនុស្សនិងសេរីភាពមូលដ្ឋាន និងគោលការណ៍ដែលមានចែងនៅក្នុងធម្មនុញ្ញសហប្រជាជាតិ កតិកាសញ្ញា និងអនុសញ្ញាអន្តរជាតិពាក់ព័ន្ធ។

(ឃ) ការបណ្តុះបណ្តាលសិស្ស និស្សិតយោធិន សម្រាប់ការរស់នៅប្រកបដោយការទទួលខុសត្រូវក្នុងសង្គមសេរី ក្នុងស្មារតីយោគយល់គ្នា សន្តិភាព អត់ឱនឲ្យគ្នា ស្មើភាពរវាងភេទ និងមិត្តភាពរវាងប្រជាជាតិទាំងអស់ ក្រុមជាតិពន្ធុ ជនជាតិ សាសនា និងជនអន្តោប្រវេសន៍។

គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ជាស្ថាប័នរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលមានតួនាទីត្រួតពិនិត្យរាល់ការរំលោភសិទ្ធិមនុស្សនិងបណ្តឹងតវ៉ានានា ប្រសិនបើមានការរំលោភបំពាន។ អនុក្រឹត្យស្តីពីបទវិន័យទូទៅសម្រាប់កងយោធពលខេមរភូមិន្ទ បានកំណត់ថាយោធិននៅក្នុងសាលាឬក្នុងមជ្ឈមណ្ឌលហ្វឹកហ្វឺន ត្រូវប្រតិបត្តិតាមបទបញ្ជាផ្ទៃក្នុងរបស់សាលាឬមជ្ឈមណ្ឌលនោះ។ យោធិនគ្រប់រូបមានសិទ្ធិក្នុងការតវ៉ាចំពោះអ្នកដែលដាក់ទណ្ឌកម្មខ្លួន។ បណ្តឹងតវ៉ានេះត្រូវធ្វើតាមរយៈនាយផ្ទាល់ ហើយបញ្ជូនតាមឋានានុក្រម។ ក្នុងរយៈពេល០៣ខែ ចាប់ពីថ្ងៃដែលបានចុះក្នុងសៀវភៅតវ៉ានៃកងឯកភាពរបស់ខ្លួនរួចមក បើមិនមានចម្លើយពីអ្នកដឹកនាំរបស់ខ្លួនផ្ទាល់ សាមីខ្លួនអាចធ្វើបណ្តឹងតវ៉ាទៅនាយកដ្ឋានអធិការកិច្ចដោយភ្ជាប់នូវសំណុំរឿងរបស់ខ្លួនមកជាមួយផង។ ក្រោយពេលទទួលបានសំណុំរឿងនេះ នាយកដ្ឋានអធិការកិច្ចត្រូវផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងការពារជាតិដើម្បីសម្រេច។

ក្រសួងការពារជាតិកំពុងតាក់តែងក្រមយុត្តិធម៌យោធា ដោយសហការជាមួយក្រសួងយុត្តិធម៌។ គណៈកម្មការជំនាញមួយត្រូវបានបង្កើតឡើងដើម្បីរ៉ាប់រងកិច្ចការនេះ។

២០- ព្រះរាជាណាចក្រកម្ពុជាមានវិធានការជាច្រើន ដើម្បីបង្ការការជ្រើសរើសកុមារឲ្យចូលកងកម្លាំងយោធិន ក្នុងនោះរួមមាន៖

- ច្បាប់ស្តីពីកាតព្វកិច្ចយោធាបញ្ញត្តថា មានតែជនដែលមានអាយុពី១៨ដល់៣០ឆ្នាំទេ ទើបច្បាប់តម្រូវឲ្យបំពេញកាតព្វកិច្ចយោធា ហើយយោធិនជាប់កិច្ចសន្យាត្រូវបានជ្រើសរើសចំពោះជនណាដែលមាន អាយុគ្រប់១៨ឆ្នាំ។

- ក្រមព្រហ្មទណ្ឌកំណត់ថា ការជម្លៀសកុមារដោយបង្ខំពីក្រុមមួយទៅក្រុមមួយផ្សេងទៀត ជាបទឧក្រិដ្ឋប្រល័យពូជសាសន៍ ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត [៤]។
- ច្បាប់ស្តីពីការអប់រំឆ្នាំ២០០៧និងកម្មវិធីនានាធានាថា ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិទទួលបានការអប់រំយ៉ាងតិច០៩ឆ្នាំ ប្រកបដោយគុណភាព ដោយឥតបង់ថ្លៃនៅសាលារៀនសាធារណៈ។
- បានផ្តល់សច្ចាប័នលើសន្ធិសញ្ញាអន្តរជាតិ ដូចជាអនុសញ្ញាស្តីពីសិទ្ធិកុមារពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ អនុសញ្ញាលេខ១៣៨ និងអនុសញ្ញាលេខ១៨២របស់អង្គការពលកម្មអន្តរជាតិ(ILO) និងលក្ខន្តិកៈក្រុងរ៉ូមនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ។
- ការតម្រូវឲ្យឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលចុះសំបុត្រកំណើតជាកាតព្វកិច្ច ដើម្បីឲ្យសមត្ថកិច្ចផ្ទៀងផ្ទាត់អាយុរបស់បុគ្គលដែលត្រូវបំពេញកាតព្វកិច្ចយោធា។
- ការលើកកម្ពស់ការយល់ដឹងនិងការបណ្តុះបណ្តាលអំពីពិធីសារនិងសន្ធិសញ្ញាអន្តរជាតិចម្បងៗស្តីអំពីសិទ្ធិមនុស្សនិងច្បាប់មនុស្សធម៌ជាអាទិ៍ ដល់យោធិននិងអ្នកជំនាញពាក់ព័ន្ធផ្សេងទៀតចំនួន៣៥នាក់ នៅខែកញ្ញា ឆ្នាំ២០០៦។ ដោយកិច្ចសហប្រតិបត្តិការនិងសហការជាមួយនឹងដៃគូអភិវឌ្ឍដូចជាអង្គការមូលនិធិសហប្រជាជាតិដើម្បីកុមារ ឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស វិទ្យាស្ថានអង្គការសហប្រជាជាតិទទួលបន្ទុកការបណ្តុះបណ្តាលនិងស្រាវជ្រាវនិងគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ។

២១- ពុំមានកុមារដែលត្រូវបានជ្រើសរើសឲ្យចូលបម្រើកងកម្លាំងយោធិនឡើយ គិតពីពេលដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើពិធីសារនេះរហូតមកដល់បច្ចុប្បន្ន។

២២- ជនស៊ីវិលដោយរាប់បញ្ចូលទាំងកុមារ មន្ទីរពេទ្យ និងសាលារៀនជាអាទិ៍ ត្រូវបានទទួលការការពារយ៉ាងពេញលេញ។ យោធិនត្រូវបានហាមឃាត់ចំពោះការបំផ្លាញឬការប្លន់ទ្រព្យសម្បត្តិប្រជាពលរដ្ឋការចាប់ចងមនុស្សយកទៅធ្វើជាថ្នូរនឹងផលប្រយោជន៍អ្វីមួយ ការប្រើហិង្សាចំពោះប្រជាពលរដ្ឋក្នុងពេលចូលកាន់កាប់ទីកន្លែងប្រយុទ្ធ ការធ្វើទោសដល់បុគ្គលទាំងឡាយដោយគ្មានការវិនិច្ឆ័យពីតុលាការការរំលោភបំពានលើរាងកាយបុគ្គល ជាពិសេសគឺហាមប្រព្រឹត្តល្មើសច្បាប់សង្គ្រាមដែលមានចែងក្នុងសន្ធិសញ្ញាអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខា[៥]។ ការបំផ្លាញឬការធ្វើឲ្យខូចខាតធ្ងន់ធ្ងរ នូវទ្រព្យសម្បត្តិដោយគ្មានហេតុផលចាំបាច់ខាងយោធាក្នុងទ្រង់ទ្រាយធំដោយខុសច្បាប់តាមទំនើងចិត្ត និងការចាប់ជនស៊ីវិលជាចំណាប់ខ្មាំងគឺជាបទឧក្រិដ្ឋសង្គ្រាម ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតយោងតាមក្រមព្រហ្មទណ្ឌឆ្នាំ២០០៩។

[៤] ក្រមព្រហ្មទណ្ឌ មាត្រា១៨៣និងមាត្រា១៨៤

[៥] មាត្រា១០និងមាត្រា១៣នៃអនុក្រឹត្យស្តីពីបទវិន័យទូទៅសម្រាប់កងយោធពលខេមរភូមិន្ទ

ក្រៅពីនេះ អំពើណាមួយដូចមានចែងខាងក្រោមនេះ គឺជាបទឧក្រិដ្ឋសង្គ្រាមដែរ កាលបើអំពើនោះត្រូវបានប្រព្រឹត្តក្នុងពេលមានជម្លោះប្រដាប់អាវុធជាលក្ខណៈអន្តរជាតិឬមិនមែនអន្តរជាតិ [៦] :

១- ការប្រើប្រាស់អាវុធដែលមានជាតិពុលឬអាវុធដែលស្ថាបនាឡើងដើម្បីបង្កការឈឺចាប់ឥតប្រយោជន៍។

២- អំពើវាយប្រហារឬទម្លាក់គ្រាប់បែកដោយចេតនា តាមមធ្យោបាយណាក៏ដោយទៅលើទីក្រុង ភូមិ ទីកន្លែងរស់នៅ ឬអគារដែលមិនមានការការពារនិងដែលមិនមែនជាគោលដៅយោធា។

៣- អំពើវាយប្រហារដោយចេតនាទៅលើមនុស្សឬសម្ភារៈដែលប្រើប្រាស់ក្នុងក្របខ័ណ្ឌនៃបេសកកម្មមនុស្សធម៌ ដោយអនុលោមតាមធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ។

៤- អំពើបង្កគ្រោះទុរ្ភិក្សដោយចេតនាដល់ប្រជាជនស៊ីវិល ដោយដកហូតនូវទ្រព្យសម្បត្តិចាំបាច់សម្រាប់បន្តការរស់រានមានជីវិតរបស់ជនស៊ីវិលទាំងនោះ។

៥- អំពើប្រើប្រាស់ជនស៊ីវិលដើម្បីបញ្ចៀសពីគោលដៅនៃប្រតិបត្តិការយោធាទៅលើអគារខ្លះ តំបន់ខ្លះនៃដែនដី ឬកងកម្លាំងយោធាខ្លះ។

៦- អំពើបំផ្លាញឬធ្វើឲ្យខូចខាតដោយចេតនានូវអគារសម្រាប់សាសនា សប្បុរសធម៌ ការអប់រំ សិល្បៈនិងវិទ្យាសាស្ត្រ វិមានប្រវត្តិសាស្ត្រ ស្នាដៃសិល្បៈឬស្នាដៃដែលមានលក្ខណៈវិទ្យាសាស្ត្រ។

៧- អំពើបង្កដល់បរិស្ថានធម្មជាតិនូវការខូចខាតដ៏ធំយូរអង្វែងនិងធ្ងន់ធ្ងរដែលមានលក្ខណៈហួសហេតុយ៉ាងជាក់ស្តែងបើប្រៀបទៅនឹងផលប្រយោជន៍ពិតប្រាកដនិងផ្ទាល់ខាងផ្នែកយោធាដែលសង្ឃឹមទុក។

៨- ការលួចប្លន់សម្បត្តិសាធារណៈឬឯកជន។

ដើម្បីធានាសុវត្ថិភាពសាធារណៈនិងបង្ការទប់ស្កាត់គ្រោះមហន្តរាយដល់អាយុជីវិតឬទ្រព្យសម្បត្តិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃឬរដ្ឋមន្ត្រីក្រសួងការពារជាតិ អាចបញ្ជាឲ្យជម្លៀសសាធារណជនចេញជាបណ្តោះអាសន្នពីលំនៅឋានឬតំបន់ ក្នុងករណីដឹងថាមានគ្រោះថ្នាក់កើតឡើង។

២៣- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការពិគ្រោះយោបល់ សម្របសម្រួលសកម្មភាពទាំងឡាយដែលពាក់ព័ន្ធនឹងបញ្ហាកុមារ ពិនិត្យ តាមដាន វាយតម្លៃលើការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារនិងលិខិតុបករណ៍អន្តរជាតិផ្សេងទៀតដែលទាក់ទងនឹងកុមារក្នុងការរៀបចំគោលនយោបាយ ផែនការ កម្មវិធីជាតិ និងសកម្មភាពផ្សេងៗ និងលើកសំណើជូនរាជរដ្ឋាភិបាលអំពីតម្រូវការនិងបញ្ហាទាំងឡាយដែលជានាឧត្តមប្រយោជន៍របស់កុមារ។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ធ្វើទំនាក់ទំនងជាមួយនឹងដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិ ដើម្បីប្តូរយោបល់ បទពិសោធ និង

---

[៦] ក្រមព្រហ្មទណ្ឌមាត្រា១៩៤

ទស្សនៈដែលទាក់ទងនឹងគោលដៅរួមក្នុងការកែលំអស្ថានភាពរបស់កុមារ។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ មានអគ្គលេខាធិការដ្ឋានមួយចែកចេញជា០៣ផ្នែកគឺ ផ្នែកការការពារកុមារនិងពិនិត្យតាមដាន ផ្នែករដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ និងផ្នែកអប់រំ ផ្សព្វផ្សាយ និងអភិវឌ្ឍធនធានមនុស្ស។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារមានអនុគណៈកម្មការចំនួន០៤និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមាររាជធានី ខេត្ត និងក្រុមការងារដើម្បីកុមារតាមក្រសួង ស្ថាប័ន ដើម្បីបំពេញកិច្ចការនិងសម្របសម្រួលការអនុវត្តអនុសញ្ញាសិទ្ធិកុមារ។ អគ្គលេខាធិការដ្ឋានមានទីតាំងស្ថិតនៅក្នុងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិជាកញ្ចប់ថវិកាដោយឡែកនៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិ ដូចជាមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ(UNICEF) អង្គការពលកម្មអន្តរជាតិ(ILO) អង្គការសង្គ្រោះកុមារ(SC) និងអង្គការមួយចំនួនទៀតដែលមានកម្មវិធីពាក់ព័ន្ធម្តងម្កាល ដូចជាអង្គការសមាជិករបស់គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ(NGOCRC) គណៈកម្មាធិការបំបាត់ពេស្យាចារ ការរំលោភ និងការជួញដូរកុមារនៅកម្ពុជា(ECPAT) សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលប្រឆាំងការជួញដូរកុមារនៅកម្ពុជា(Cambodia ACTs) និងអ្នកតំណាងគម្រោងអន្តរៈទីភ្នាក់ងារសហប្រជាជាតិប្រឆាំងអំពើជួញដូរមនុស្ស(UNIAP) អង្គការអ៊ីនធ័រវីតា(Intervita) អង្គការអេវរីឆាល(Every Child) អង្គការឆាលហ្វាន់(Child Fund) និងអង្គការសម្ព័ន្ធភាពខ្មែរប្រយុទ្ធនឹងជំងឺអេដស៍(Khana)។

២៤- បន្ថែមពីលើកម្មវិធីសិក្សាស្តីពីសិទ្ធិកុមារ ការអប់រំអំពីសន្តិភាពត្រូវបានដាក់បញ្ចូលទៅក្នុងមុខវិជ្ជាអក្សរសាស្ត្រខ្មែរនិងពលរដ្ឋវិជ្ជានៅក្នុងកម្មវិធីសិក្សារបស់អនុវិទ្យាល័យ។ រៀងរាល់ឆ្នាំ នាយកដ្ឋានយុវជននៃក្រសួងអប់រំ យុវជន និងកីឡា បានបើកវគ្គបណ្តុះបណ្តាលអនុសញ្ញាស្តីពីសិទ្ធិកុមារដល់នាយកនាយករង លោកគ្រូ អ្នកគ្រូ និងកុមារជាសមាជិកក្រុមប្រឹក្សាកុមារ នៅតាមសាលាបឋមសិក្សា និងអនុវិទ្យាល័យនៅទូទាំង២៤រាជធានី ខេត្ត។ កុមារទាំងនោះ ត្រូវបានសួរសាកល្បងពីសិទ្ធិកុមារដើម្បីវាយតម្លៃលើការយល់ដឹង ដោយមានការជូនរង្វាន់ជ័យលាភីព្រមទាំងផ្សព្វផ្សាយតាមរយៈទូរទស្សន៍ វិទ្យុ និងសារព័ត៌មាន។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានធ្វើសកម្មភាពផ្សព្វផ្សាយសិទ្ធិកុមារដល់ប្រជាពលរដ្ឋក្នុងសហគមន៍និងកុមារជាសិស្សសាលា តាមរយៈការបញ្ចាំងវីដេអូ ខិត្តបណ្ណផ្សព្វផ្សាយ ផ្ទាំងរូបភាព និងកូនសៀវភៅដែលមានរូបភាពនិងខ្លឹមសារខ្លីៗងាយយល់។

២៥- ជាទូទៅក្នុងការប្រមូលទិន្នន័យ យើងបានអនុវត្តតាមច្បាប់ស្តីពីស្ថិតិដែលគ្រប់គ្រងលើផ្នែកទាំងអស់ទាក់ទងនឹងការប្រមូលដំណើរការចងក្រង ការវិភាគ ការបោះពុម្ព និងការផ្សព្វផ្សាយទិន្នន័យក្នុងទូទាំងប្រទេសកម្ពុជា ហើយផ្អែកលើមាត្រា១១នៃច្បាប់នេះ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការទទួលខុសត្រូវក្នុងកិច្ចការនេះ។ កន្លងមក វិទ្យាស្ថានជាតិស្ថិតិបានចងក្រងព័ត៌មានអំពីកម្ពុជា(CAMInfo) ហើយបង្កើតទិន្នន័យសូចនាករសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ដោយផ្អែកលើដេហ្វអ៊ីនហ្វូ(DevInfo)។ ព័ត៌មានអំពីកម្ពុជា(CAMInfo) បានបញ្ចូលទិន្នន័យអំពីការអនុវត្តអនុសញ្ញាសិទ្ធិកុមារ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ពិភពលោកមួយសមស្របសម្រាប់កុមារ(WFFC) និងគោលដៅ

ពិភពលោក តំបន់ និងជាតិដទៃផ្សេងៗទៀត។ ទិន្នន័យទាំងនេះ ត្រូវបានវិទ្យាស្ថានជាតិស្ថិតិធ្វើបច្ចុប្បន្នកម្ម០២ដងក្នុងមួយឆ្នាំ។ ក្នុងឆ្នាំ២០០៦ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មានស្តីពីការការពារកុមារ ដើម្បីប្រមូលព័ត៌មានពីគ្រប់ស្ថាប័ននិងអង្គការដែលបានធ្វើសកម្មភាពលើវិស័យការពារកុមារ អាចឲ្យយើងដឹងពីប្រភេទអតិថិជនដែលគេធ្វើការជាមួយនិងប្រភេទសេវាកម្មដែលគេផ្តល់ឲ្យ និងស្គាល់ពីទីកន្លែងដែលអាចឲ្យស្រាវជ្រាវរកទិន្នន័យដ៏ជាក់លាក់មួយដើម្បីចែករំលែកជូនគ្នាទៅវិញទៅមក ជាពិសេស ជួយតម្រង់ទិសឲ្យមានភាពងាយស្រួលក្នុងទំនាក់ទំនងនឹងការការពារកុមារ តាមស្ថាប័នឬអង្គការនានាតាមតម្រូវការភ្លាមៗ។

បច្ចុប្បន្ន ព័ត៌មាននេះត្រូវបានក្រុមការងារថ្នាក់ជាតិពហុវិស័យធ្វើសហការជាមួយអង្គការស៊ីដ (Sead) ដើម្បីស្រង់យកទិន្នន័យរបស់គម្រោងប្រព័ន្ធគ្រប់គ្រងព័ត៌មានកិច្ចការពារកុមារ និងសៀវភៅសេវាសង្គមកិច្ចរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីបង្កើតជាសៀវភៅសេវាកម្មសង្គមកិច្ច សម្រាប់អ្នកដែលងាយរងគ្រោះ ដោយមានការទទួលស្គាល់ដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ នៅក្នុងសៀវភៅនេះ មានអង្គការមិនមែនរដ្ឋាភិបាលចំនួន២៨០(ធ្វើការនៅ៩០៥ទីតាំង) បណ្តាញអង្គការដៃគូចំនួន២ មន្ទីរពេទ្យរដ្ឋចំនួន៨៥ និងមណ្ឌលសុខភាពចំនួន២២០។

ក្រៅពីសមិទ្ធផលដែលបានរៀបរាប់ក្នុងរបាយការណ៍នេះ ពុំទាន់មានការវាយតម្លៃទូលំទូលាយដើម្បីវាស់វែងសមិទ្ធផលនៃការអនុវត្តពិធីសារនេះទេ។

## ការហាមឃាត់និងបញ្ហាពាក់ព័ន្ធ

ឆ្លើយតបនឹងមាត្រា១ មាត្រា២ និងមាត្រា៤ កថាខណ្ឌទី១និងកថាខណ្ឌទី២នៃពិធីសារបន្ថែម។

២៦- មិនមាននិយមន័យនៃការចូលរួមដោយផ្ទាល់និងការជ្រើសរើសដោយបង្ខិតបង្ខំ ក៏ដូចជាបទល្មើសដែលមានចែងនៅក្នុងមាត្រា៤នៃពិធីសារនៅក្នុងច្បាប់និងបទបញ្ញាជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជាទេ។ ចាប់តាំងពីបញ្ចប់ជម្លោះផ្ទៃក្នុង នៅក្នុងព្រះរាជាណាចក្រកម្ពុជាមិនមានកងកម្លាំងប្រដាប់អាវុធជាកុមារអាយុក្រោម១៨ឆ្នាំឡើយ។

នៅឆ្នាំ២០០៤ ស្ថាប័ននីតិប្បញ្ញត្តិកម្ពុជាបានអនុម័តច្បាប់ដើម្បីបង្កើតតុលាការស៊ើបអង្កេតនូវឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ (របបប៉ុលពត ១៩៧៥-១៩៧៩) ដែលក្នុងពេលនោះពួកមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យបានប្រើកម្លាំងរបស់កុមារអាយុក្រោម១៨ឆ្នាំធ្វើជាឧបករណ៍សម្រាប់បង្កឧក្រិដ្ឋកម្មផ្សេងៗ ដែលសង្គមជាតិទាមទារឲ្យមានការកាត់ទោសក្រោមសមត្ថកិច្ចតុលាការ[៧]។ តុលាការនេះ ត្រូវបាន ហៅថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

អំពើបង្ខំឈ្លើយសឹកឬជនស៊ីវិលឲ្យបម្រើក្នុងកងកម្លាំងយោធិនរបស់សត្រូវគឺជាបទឧក្រិដ្ឋកម្មសង្គ្រាមដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតនិងត្រូវទទួលទោសបន្ថែមផ្សេងទៀត។

[៧] អនុលោមតាមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦

ចំពោះនីតិបុគ្គល ក្រៅពីត្រូវទទួលទោសបន្ថែមមួយឬច្រើន ត្រូវពិន័យជាប្រាក់ពីហាសិបលានរៀល ទៅប្រាំរយលានរៀល។ យោងតាមមាត្រា២៩នៃក្រមព្រហ្មទណ្ឌ អ្នកសមគំនិតនៃបទឧក្រិដ្ឋឬបទមជ្ឈិមត្រូវផ្តន្ទាទោសដូចគ្នានឹងចារីដែរ។

២៧- ដើម្បីអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ ព្រះរាជាណាចក្រកម្ពុជាបានអនុម័តច្បាប់ពាក់ព័ន្ធនិងបទបញ្ជា ដូចមានបង្ហាញជូនក្នុងវាក្យខណ្ឌទី១ដល់វាក្យខណ្ឌទី៥ កថាខណ្ឌទី១ ចំណុចទាំង៥នៃចំណុចទី១៧នៃរបាយការណ៍នេះ។

២៨- ព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគីនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។ លើសពីនេះ ព្រះរាជាណាចក្រកម្ពុជាក៏ជារដ្ឋភាគីនៃសន្ធិសញ្ញាខាងក្រោម៖

(ក) ពិធីសារបន្ថែម (១)និង (២) ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ (ផ្តល់សច្ចាប័នឆ្នាំ១៩៩៨)

(ខ) លក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិឆ្នាំ១៩៩៨ (ផ្តល់សច្ចាប័នឆ្នាំ២០០២)

(គ) អនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ១៨២ ដែលពាក់ព័ន្ធទៅនឹងការហាមឃាត់និងសកម្មភាពបន្ទាន់ដើម្បីលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារឆ្នាំ១៩៩៩(ផ្តល់សច្ចាប័នឆ្នាំ២០០៦)។

២៩- ព្រះរាជាណាចក្រកម្ពុជាគ្មានយោធាឯកជនទេ។ នីតិបុគ្គល ដូចជាក្រុមហ៊ុនសន្តិសុខ ជាអាទិ៍ ត្រូវទទួលខុសត្រូវចំពោះអំពើនិងសកម្មភាពដែលមានចែងក្នុងពិធីសារ។ មាត្រា៤២នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ចែងថា " នៅក្នុងករណីដែលមានចែងជាក់លាក់ក្នុងច្បាប់និងបទដ្ឋានគតិយុត្តផ្សេងទៀត នីតិបុគ្គលលើកលែងតែរដ្ឋចេញ អាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទល្មើសដែលប្រព្រឹត្តដោយអង្គការឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ។ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល មិនលើកលែងនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលក្នុងអំពើដដែលនោះទេ"។ យោងតាមប្រកាសលេខ៣៥៥៧ប្រក ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងកម្លាំងសន្តិសុខឯកជន រាជរដ្ឋាភិបាលអនុញ្ញាតឲ្យបង្កើតក្រុមហ៊ុនសន្តិសុខឯកជនធ្វើអាជីវកម្ម និងគ្រឹះស្ថានឯកជនដែលបង្កើតនិងប្រើប្រាស់កម្លាំងសន្តិសុខផ្ទាល់ខ្លួនពុំធ្វើអាជីវកម្ម។ កម្លាំងសន្តិសុខឯកជនស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រុមត្រួតពិនិត្យលើសកម្មភាពរបស់ក្រុមហ៊ុនសេវាកម្មសន្តិសុខឯកជន។ កុមារអាយុក្រោម១៨ឆ្នាំ ពុំត្រូវបានអនុញ្ញាតឲ្យចូលបម្រើក្នុងកងកម្លាំងសន្តិសុខឯកជនឡើយ។

៣០- ការធ្វើបត្យាប័នបុគ្គលដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើសទាក់ទងនឹងការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ ដូចដែលមានកំណត់នៅក្នុងពិធីសារនិងបទល្មើសព្រហ្មទណ្ឌផ្សេងៗទៀតត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌទាក់ទងនឹងការធ្វើបត្យាប័ន។ បត្យាប័នជនបរទេសដែលត្រូវចាប់ខ្លួននៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានគ្រប់គ្រងដោយបទប្បញ្ញត្តិនៃសន្ធិសញ្ញានិងអនុសញ្ញាអន្តរជាតិដែលទទួលសច្ចាប័នពីព្រះរាជាណាចក្រកម្ពុជា។ ក្នុងករណីគ្មានសន្ធិសញ្ញាឬអនុសញ្ញាអន្តរជាតិដែលទទួលសច្ចាប័នពីព្រះរាជាណាចក្រកម្ពុជាទេ បទប្បញ្ញត្តិនៃជំពូកស្តីពីបត្យាប័នត្រូវយកមកអនុវត្តលើកលែងតែមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ផ្សេងទៀត។

បត្យាប័នអាចធ្វើទៅបាន លុះត្រាតែអំពើដែលត្រូវចោទប្រកាន់លើបុគ្គលដែលគេទាមទារនោះ ជាបទល្មើសតាមច្បាប់របស់រដ្ឋដែលធ្វើសំណើផង និងតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាផង។ គ្រប់ពាក្យសុំធ្វើបត្យាប័នត្រូវតែជូនរាជរដ្ឋាភិបាលកម្ពុជាតាមផ្លូវទូត។ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិកម្ពុជាបញ្ជូនពាក្យសុំឲ្យធ្វើបត្យាប័ននិងលិខិតបញ្ជាក់ភស្តុតាងទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ផ្ទៀងផ្ទាត់មើលនិយ័តភាពនៃពាក្យសុំនិងបញ្ជូនពាក្យនោះទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ភ្នំពេញ។ សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញ ជាអង្គការតែមួយគត់ដែលមានសមត្ថកិច្ចដើម្បីពិចារណាលើនិយ័តភាពនៃបត្យាប័នដែលរាជរដ្ឋាភិបាលកម្ពុជាបានទទួល។ ព្រះរាជាណាចក្រកម្ពុជា មានកិច្ចព្រមព្រៀងបត្យាប័នជាមួយនឹងប្រទេសមួយចំនួនដូចជា ព្រះរាជាណាចក្រថៃ សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងសាធារណរដ្ឋកូរ៉េ។ រហូតមកដល់ពេលនេះ មិនមានការស្នើសុំឲ្យប្រទេសណាមួយធ្វើបត្យាប័នជនដែលប្រព្រឹត្តបទល្មើសនឹងអំពើដែលមានកំណត់ក្នុងពិធីសារ មកព្រះរាជាណាចក្រកម្ពុជានោះឡើយ។

## កិច្ចការពារ ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្ម

ឆ្លើយតបនឹងមាត្រា៦ កថាខណ្ឌទី៣នៃពិធីសារបន្ថែម។

៣១- កម្មវិធីរំសាយយោធិនចាប់ផ្តើមក្នុងឆ្នាំ១៩៩៩ តាមរយៈគម្រោងស្តីពីការកាត់រំសាយនិងការធ្វើសមាហរណកម្ម។ គម្រោងនេះមានគោលដៅឲ្យយោធិនដែលត្រូវកាត់រំសាយវិលត្រឡប់ទៅកាន់ជីវភាពស៊ីវិលវិញប្រកបដោយជោគជ័យ និងរួមវិភាគទានដល់ការរៀបចំធនធានថវិកាឡើងវិញ ដើម្បីយកទៅប្រើប្រាស់ក្នុងវិស័យអប់រំ សុខាភិបាល កសិកម្ម និងអភិវឌ្ឍជនបទ។ គម្រោងនេះផ្តល់មូលនិធិដោយធនាគារពិភពលោក ប្រទេសស៊ុយអែត ប្រទេសហូឡង់ ប្រទេសជប៉ុន កម្មវិធីស្បៀងអាហារពិភពលោក និងថវិកាបដិភាគពីរាជរដ្ឋាភិបាលកម្ពុជា។ រាជរដ្ឋាភិបាលបានបង្កើតក្រុមប្រឹក្សាកាត់រំសាយយោធិន(Council for Demobilization of Armed Forces = CDAF) ដែលជាអង្គភាពទទួលខុសត្រូវក្នុងការកាត់រំសាយទ័ពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រុមប្រឹក្សានេះមានបេសកកម្មក្នុងការផ្តួចផ្តើមនិងជំរុញការដោះស្រាយបញ្ហារំសាយកងកម្លាំងប្រដាប់អាវុធ។ ពុំមានរបាយការណ៍ណាថាយោធិនត្រូវបានរំសាយជាកុមារអាយុក្រោម១៨ឆ្នាំឡើយ។

កម្មវិធីរំសាយយោធិនទាំងមូលត្រូវបានអនុវត្តដោយរាជរដ្ឋាភិបាលនិងមានការចូលរួមពីមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ(UNICEF)និងដៃគូអភិវឌ្ឍផ្សេងទៀត ដើម្បីឆ្លើយតបទៅនឹងតម្រូវការអប់រំដល់កុមារដែលជាកូនចៅរបស់យោធិនត្រូវបានរំសាយមិនមានឱកាសរៀនសូត្រក្នុងពេលកន្លងមក ដើម្បីទទួលបាននូវសេវាអប់រំកម្រិតបឋមសិក្សាឲ្យបានប្រសើរ។ មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ(UNICEF) បានគាំទ្ររាជរដ្ឋាភិបាលដើម្បីចាប់ផ្តើមកម្មវិធីនេះក្នុងឆ្នាំ២០០១ ក្នុងគោលបំណងជួយកុមារដែលជួបការលំបាកឲ្យបានទទួលសេវាអប់រំទាន់ពេលវេលា។ ដោយសារ

ខ្វះខាតធនធានហិរញ្ញវត្ថុនិងធនធានមនុស្ស ហើយការរំសាយយោធិនជាកម្មវិធីថ្មីសន្លាងមួយសម្រាប់ព្រះរាជាណាចក្រកម្ពុជានោះ ហេតុនេះមិនមានការបណ្តុះបណ្តាលផ្នែកច្បាប់ ផ្នែកចិត្តសាស្ត្រ និងការបណ្តុះបណ្តាលដទៃទៀតសម្រាប់អ្នកដែលធ្វើការជាមួយយោធិនដែលត្រូវបានរំសាយនោះឡើយ។

៣២- រហូតមកដល់ពេលនេះពុំមានរបាយការណ៍ស្តីពីករណីប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិដែលត្រូវបានហាមដោយពិធីសារនេះឡើយ។ ដូច្នេះព្រះរាជាណាចក្រកម្ពុជា ពុំដែលមានកម្មវិធីរំសាយយោធិនជាកុមាររបស់ផ្នែកសាធារណៈ និងផ្នែកឯកជននៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ។

## ជំនួយនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ

ឆ្លើយតបនឹងមាត្រា៧ កថាខណ្ឌទី១នៃពិធីសារបន្ថែម។

៣៣- ព្រះរាជាណាចក្រកម្ពុជាបានទទួលជំនួយនិងកិច្ចសហការពីអន្តរជាតិដើម្បីអនុវត្តពិធីសារនេះ ដូចជាជំនួយលើការកាត់បន្ថយអាវុធរបស់សហភាពអឺរ៉ុប(EU-ASAC)និងជប៉ុន(JSAC)។ មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ(UNICEF) និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា(OHCHR) បានរួមចំណែកក្នុងការផ្សព្វផ្សាយពិធីសារតាមរយៈការបោះពុម្ពផ្សាយ និងការបណ្តុះបណ្តាល។ នៅឆ្នាំ២០០៦ ក្រោមគំនិតផ្តួចផ្តើមរបស់ក្រសួងការពារជាតិនិងវិទ្យាស្ថានអង្គការសហប្រជាជាតិ សម្រាប់ការបណ្តុះបណ្តាល និងការសិក្សាស្រាវជ្រាវ (UNITAR) មានការបណ្តុះបណ្តាលអំពីពិធីសារក្នុងចំណោមប្រធានបទដទៃទៀតទាក់ទងនឹងសេចក្តីត្រូវការរបស់ស្ត្រីនិងកុមារនៅក្នុងជម្លោះប្រដាប់អាវុធ ដល់ក្រុមអ្នកដោះមីនកម្ពុជាដែលត្រូវបំពេញបេសកកម្មរក្សាសន្តិភាពនៅក្រៅប្រទេស និងគ្រូឧទ្ទេសនាមជាយោធិនមួយចំនួន។

ព្រះរាជាណាចក្រកម្ពុជាជួបប្រទះសង្គ្រាមនៅតាមព្រំដែន ដែលធ្វើឲ្យប្រជាពលរដ្ឋរាប់ម៉ឺនគ្រួសាររត់ភៀសសឹក ក្នុងនោះភាគច្រើនជាស្ត្រីនិងកុមារ ហើយដែលធ្វើឲ្យមានផលប៉ះពាល់ដល់ការអប់រំ សុខភាព អនាម័យ និងស្ថានភាពរស់នៅ។ ក្នុងកាលៈទេសៈនេះ កាកបាទក្រហមកម្ពុជាបានផ្តល់ជំនួយយ៉ាងសន្ធឹកសន្ធាប់ដល់ជនរងគ្រោះទាំងនោះ ដូចជា ជម្រក ស្បៀងអាហារ ទឹកស្អាត សេវាថែទាំសុខភាពជាដើម។

៣៤- ព្រះរាជាណាចក្រកម្ពុជាបាននិងកំពុងសហការយ៉ាងជិតស្និទ្ធជាមួយនឹងអង្គការមូលនិធិសហប្រជាជាតិដើម្បីកុមារនិងអង្គការដទៃទៀតដែលធ្វើការដើម្បីនិង/ឬជាមួយកុមារ។ វិធានការដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិពាក់ព័ន្ធនឹងការអនុវត្តពិធីសារនេះ មានជាអាទិ៍៖

- ការអនុញ្ញាតឲ្យទីភ្នាក់ងារអង្គការសហប្រជាជាតិចូលរួមក្នុងដំណើរការពិគ្រោះយោបល់ក្នុងការធ្វើរបាយការណ៍នេះ
- ការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារនិងពិធីសារ ក៏ដូចជាកិច្ចព្រមព្រៀងពាក់ព័ន្ធផ្សេងទៀតនៅក្នុងក្របខ័ណ្ឌតំបន់និងអន្តរជាតិ។

៣៥- ព្រះរាជាណាចក្រកម្ពុជាពុំមែនជាប្រទេសផលិតនិងធ្វើពាណិជ្ជកម្មអាវុធឡើយ។ មាត្រា៥៣នៃរដ្ឋធម្មនុញ្ញចែងថា "ព្រះរាជាណាចក្រកម្ពុជាប្រកាន់ខ្ជាប់ជានិច្ចនូវនយោបាយអព្យាក្រឹត អចិន្ត្រៃយ៍ និង

មិនចូលបក្សសម្ព័ន្ធ។ ព្រះរាជាណាចក្រកម្ពុជារួមរស់ដោយសន្តិសហវិជ្ជមានជាមួយប្រទេសជិតខាង និងប្រទេសដទៃទៀតទាំងអស់នៅលើសកលលោក។ ព្រះរាជាណាចក្រកម្ពុជាមិនឈ្លានពានប្រទេសណាដាច់ខាត មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃប្រទេសដទៃដោយផ្ទាល់ឬដោយប្រយោល ទោះបីក្រោមរូបភាពណាក៏ដោយ ហើយដោះស្រាយរាល់បញ្ហាដោយសន្តិវិធី និងគោរពផលប្រយោជន៍ផងគ្នាទៅវិញទៅមក។ ព្រះរាជាណាចក្រកម្ពុជាមិនអនុញ្ញាតឲ្យមានមូលដ្ឋានយោធាបរទេសនៅលើទឹកដីរបស់ខ្លួន ហើយក៏មិនអនុញ្ញាតឲ្យមានមូលដ្ឋានយោធារបស់ខ្លួននៅបរទេសដែរ លើកលែងតែក្នុងក្របខ័ណ្ឌនៃសំណូមពររបស់អង្គការសហប្រជាជាតិ។ ប៉ុន្តែ ព្រះរាជាណាចក្រកម្ពុជារក្សាសិទ្ធិទទួលយកជំនួយបរទេសជាសម្ភារៈយោធា អាវុធ គ្រាប់រំសេវ ការហ្វឹកហ្វឺនកងកម្លាំងប្រដាប់អាវុធ និងជំនួយផ្សេងៗទៀត ដើម្បីការពារខ្លួននិងធានាសណ្តាប់ធ្នាប់និងសន្តិសុខសាធារណៈនៅផ្ទៃក្នុងប្រទេស"។ ដូច្នេះព្រះរាជាណាចក្រកម្ពុជាមិនអនុវត្តគោលនយោបាយធ្វើពាណិជ្ជកម្មនិងការនាំចេញអាវុធខ្នាតតូចនិងអាវុធធុនស្រាលឡើយ។

៣៦- កងយោធពលខេមរភូមិន្ទបានចូលរួមនៅក្នុងបេសកកម្មសន្តិភាពរបស់អង្គការសហប្រជាជាតិនៅទ្វីបអាហ្វ្រិកនៅក្នុងផ្នែកសំខាន់៣គឺ ការដោះមីន វិស្វកម្ម និងការសង្កេតការណ៍។ ព្រះរាជាណាចក្រកម្ពុជាបានធ្វើជាម្ចាស់ផ្ទះសម្រាប់លំហាត់ហ្វឹកហ្វឺនប្រតិបត្តិការសន្តិភាពពហុសាសន៍នៅឆ្នាំ២០១០នេះ។

៣៧- ស្ថានភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជាពុំត្រូវបានកត់សំគាល់នៅក្នុងរបាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិយោងតាមសេចក្តីសម្រេចចិត្តលេខ១៦១២ ឆ្នាំ២០០៥ទេ។

## **បទប្បញ្ញត្តិច្បាប់ដទៃទៀត**

ឆ្លើយតបនឹងមាត្រា៥នៃពិធីសារបន្ថែម។

៣៨- បទប្បញ្ញត្តិនៃច្បាប់ជាតិជាធរមាននិងបទប្បញ្ញត្តិនៃច្បាប់អន្តរជាតិមានលក្ខណៈចងកាតព្វកិច្ចចំពោះព្រះរាជាណាចក្រកម្ពុជាដែលត្រូវបានពិចារណាថាមានភាពល្អប្រសើរជាងបទប្បញ្ញត្តិនៃពិធីសារ រួមមាន៖

១-មាត្រា៤៨នៃរដ្ឋធម្មនុញ្ញ ផ្តល់នូវការគាំពារពិសេសដល់កុមារក្នុងស្ថានការណ៍មានសង្គ្រាមនិងគាំពារកុមារប្រឆាំងនឹងការងារទាំងឡាយដែលអាចធ្វើឲ្យខូចដល់ការអប់រំនិងការរៀនសូត្ររបស់កុមារ ឬដែលនាំឲ្យអន្តរាយដល់សុខភាពឬសុខុមាលភាពរបស់កុមារ។ ច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទនិងច្បាប់ស្តីពីកាតព្វកិច្ចយោធា មានបទប្បញ្ញត្តិដាច់ខាតដែលកំណត់ថា យោធិនអាជីព យោធិនជាប់កិច្ចសន្យា និងយោធិនបំពេញកាតព្វកិច្ចយោធាបានជ្រើសរើសចំពោះជនណាដែលមានអាយុគ្រប់១៨ឆ្នាំនិងមានសម្បទាតាមតម្រូវការដើម្បីបំពេញមុខងារ ដូចមានចែងក្នុងប្រកាសរួមរបស់ក្រសួងការពារជាតិនិងក្រសួងសុខាភិបាលខែសីហាឆ្នាំ២០១០ ស្តីពីលក្ខខណ្ឌកាយសម្បទានិងសុខភាពប្រជាពលរដ្ឋជាប់កាតព្វកិច្ចយោធា។ ដូច្នេះពុំមានអញ្ញត្រកម្មដោយបង្កើនអាយុនិងលក្ខខណ្ឌកាយសម្បទាដើម្បីឲ្យកុមារចូលរួមក្នុងជម្លោះប្រដាប់អាវុធឡើយ។

២- ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើពិធីសារបន្ថែមទី១នៃអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ទាក់ទងនឹងការការពារជនរងគ្រោះ ដោយជម្លោះប្រដាប់អាវុធអន្តរជាតិនៅឆ្នាំ១៩៩៨។ មាត្រា៧៧នៃពិធីសារទីនេះចែងថា កុមារជាកម្មវត្ថុនៃការការពារពិសេស និងត្រូវបានការពារពីគ្រប់ទម្រង់នៃការបៀតបៀនវាយប្រហារ។ គូភាគីក្នុងជម្លោះប្រដាប់អាវុធត្រូវផ្តល់ការថែទាំនិងជំនួយដែលកុមារត្រូវការដោយហេតុថាកុមារស្ថិតក្នុងអាយុជាកុមារឬដោយហេតុផលផ្សេងពីនេះ។ គូភាគីក្នុងជម្លោះត្រូវចាត់វិធានការសមស្របគ្រប់យ៉ាងដើម្បីបង្ការកុមារ អាយុក្រោម១៥ឆ្នាំ ឲ្យរួចពីការចូលរួមដោយផ្ទាល់ក្នុងអរិភាព ជាពិសេសត្រូវបញ្ឈប់ការជ្រើសរើសកុមារឲ្យចូលបម្រើក្នុងកងកម្លាំងប្រដាប់អាវុធ។ មាត្រា៧៨ចែងថា គ្មានភាគីណាមួយក្នុងជម្លោះប្រដាប់អាវុធ អាចធ្វើការជម្លៀសកុមារឲ្យចេញពីប្រទេសរបស់កុមារទៅបរទេសឡើយ លើកលែងតែករណីជម្លៀសជាបណ្តោះអាសន្នដែលមានមូលហេតុបង្ខំខាងសុខភាពឬការព្យាបាលផ្នែកវេជ្ជសាស្ត្រសម្រាប់កុមារ ឬលើកលែងតែនៅក្នុងដែនដីដែលត្រូវបានកាន់កាប់ សុវត្ថិភាពរបស់កុមារតម្រូវឲ្យធ្វើយ៉ាងនោះ។ ករណីកុមារមានឪពុកម្តាយឬអ្នកអាណាព្យាបាលស្របច្បាប់ ត្រូវមានការយល់ព្រមលើការជម្លៀសពីអ្នកទាំងនោះ។

៣- ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាទីក្រុងហ្សឺណែវស្តីពីការការពារជនស៊ីវិលក្នុងពេលមានសង្គ្រាមនៅឆ្នាំ១៩៥៨។ មាត្រា២៤នៃអនុសញ្ញានេះចែងពីវិធានការចាំបាច់ ដើម្បីធានាថាកុមារអាយុក្រោម១៥ឆ្នាំ ដែលកំព្រាឬត្រូវបានបំបែកពីឪពុកម្តាយដោយសារសង្គ្រាមមិនត្រូវបានគេទុកចោល ហើយការថែទាំកុមារ ការប្រតិបត្តិសាសនាដោយកុមារ និងការអប់រំកុមារត្រូវបានសម្របសម្រួលនៅគ្រប់កាលៈទេសៈ។

៤- ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើពិធីសារបន្ថែមទី II នៃអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ទាក់ទងនឹងការការពារជនរងគ្រោះដោយជម្លោះប្រដាប់អាវុធ ដែលពុំមានចរិតអន្តរជាតិនៅឆ្នាំ១៩៩៨។ ឆ្លងកាត់បទពិសោធសង្គ្រាមជាច្រើនទសវត្សរ៍ ព្រះរាជាណាចក្រកម្ពុជាបានពង្រឹងបន្ថែមនូវការការពារដល់ជនរងគ្រោះ ជាពិសេសកុមារ ពីជម្លោះប្រដាប់អាវុធដែលពុំមានចរិតអន្តរជាតិ ដោយធ្វើការដាក់កំហិតលើរបៀបធ្វើសង្គ្រាម។

៥- ព្រះរាជាណាចក្រកម្ពុជាបានធ្វើការប្តេជ្ញាចិត្តនៅក្នុងក្របខ័ណ្ឌអន្តរជាតិ ជាពិសេសក្នុងក្របខ័ណ្ឌអាស៊ានដើម្បីៈ

- ការពារនិងលើកស្ទួយភាពជាដៃគូដើម្បីសន្តិភាពនិងវិបុលភាពនៅក្នុងពិភពលោក
- ប្រយុទ្ធប្រឆាំងភេរវកម្មអន្តរជាតិ
- បង្ក្រាបការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ
- លុបបំបាត់អំពើហិង្សាលើស្ត្រីនៅក្នុងតំបន់អាស៊ាន។

## សេចក្តីសន្និដ្ឋាន

៣៩- ទោះបីជាមានជម្លោះព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជានិងព្រះរាជាណាចក្រថៃក្តីក៏ពុំមានកុមារព្រះរាជាណាចក្រកម្ពុជាណាម្នាក់ចូលរួមក្នុងជម្លោះប្រដាប់អាវុធឡើយ។ ព្រះរាជាណាចក្រកម្ពុជាបាននិងកំពុងយកចិត្តទុកដាក់ចំពោះប្រជាជនភៀសសឹក ជាពិសេសកុមារភៀសសឹក តាមរយៈការការពារសុវត្ថិភាព ការផ្តល់ជំនួយសង្គ្រោះបន្ទាន់ ការផ្តល់ជម្រកបណ្តោះអាសន្ន និងការធានាថាកុមារដែលកំពុងរស់នៅក្នុងតំបន់ដែលទទួលរងការឈ្លានពានពីកងទ័ពព្រះរាជាណាចក្រថៃ ឲ្យទទួលបាននូវឱកាសអប់រំនិងទទួលបានសេវាសុខភាព ដូចកុមារនៅក្នុងតំបន់ផ្សេងៗទៀតនៅទូទាំងប្រទេស។

**ឧបសម្ព័ន្ធ**

- ច្បាប់ស្តីពីកាតព្វកិច្ចយោធាឆ្នាំ២០០៦
- ច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទឆ្នាំ១៩៩៧
- អនុក្រឹត្យស្តីពីបទវិន័យទូទៅសម្រាប់កងយោធពលខេមរភូមិន្ទឆ្នាំ២០០២
- អនុក្រឹត្យស្តីពីលក្ខខណ្ឌនិងបែបបទនៃការធ្វើជំរឿន ការជ្រើសរើស ការអញ្ជើញ ការពន្យារពេលសម្រាប់យុវជនកំពុងជាប់ការសិក្សា ប្រជាពលរដ្ឋដែលស្ថិតក្នុងករណីពិសេស និងការអនុវត្តច្បាប់ស្តីពីកាតព្វកិច្ចយោធាឆ្នាំ២០០៩។

**អត្ថបទយោង**

- ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣
- ជំរឿនទូទៅនូវប្រជារាស្រ្តរបស់ប្រទេសកម្ពុជាឆ្នាំ២០០៨
- របាយការណ៍អនុវត្តសេចក្តីសម្រេចចិត្តលេខ២០០៩/២៦ របស់ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមកិច្ចស្តីពីកិច្ចខិតខំប្រឹងប្រែងជាតិនិងអន្តរជាតិដើម្បីកំណែទម្រង់យុត្តិធម៌កុមារឆ្នាំ២០១០
- របាយការណ៍លើកទី២និងទី៣របស់កម្ពុជា ស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារពីឆ្នាំ២០០០ដល់ឆ្នាំ២០០៧
- តារាងស្តីពីសន្ធិសញ្ញា/កិច្ចព្រមព្រៀងអាស៊ាន និងការផ្តល់សច្ចាប័ន ខែមិថុនា ឆ្នាំ២០១០
- លទ្ធផលកិច្ចប្រជុំស្តីពីការបង្ហាញគោលការណ៍ណែនាំថ្មីរបស់អង្គការសហប្រជាជាតិ សម្រាប់ធ្វើរបាយការណ៍អំពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១០
- លទ្ធផលកិច្ចប្រជុំជាមួយវិទ្យាស្ថានតស៊ូមតិនិងគោលនយោបាយ ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១០
- នយោបាយការពារជាតិនៃព្រះរាជាណាចក្រកម្ពុជា(សៀវភៅសការពារជាតិ) ឆ្នាំ២០០៦
- Implementation Completion Report on a Loan/Credit/Grant to Cambodia for a Demobilization and Reintegration Project, 22 May, 2006.